ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ២៨២ សហវ

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែ មិនា ឆ្នាំ ២០០២

# ប្រកាស

## ស្តីពី

## ការបោះផ្សាយសញ្ញាប័ណ្ណរដ្ឋ ដើម្បីបំពេញដើមទុនអោយ ក្រុមហ៊ុនជាតិធានារ៉ាប់រងកម្ពុជា «កាមិនកូ»

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម លេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៧០០/០២ ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការធានារ៉ាប់រង
- បានឃើញព្រះរាជក្រម លេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ហើយត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩
- បានឃើញព្រះរាជក្រម នស/រកម/១២០១/១៥ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ២០០២
- បានឃើញអនុក្រឹត្យ លេខ ១០៦ អនក្រ ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០១ ស្តីពី ការធានារ៉ាប់រង
- បានឃើញអនុក្រឹត្យ លេខ ១៣២ អនក្រ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពី ការបង្កើតក្រុមហ៊ុនជាតិធានារ៉ាប់រងកម្ពុជា «កាមិនកូ»៕

## សំរេច

**ប្រការ ១-**

បោះផ្សាយសញ្ញាប័ណ្ណរដ្ឋ សំរាប់បំពេញដើមទុនអោយក្រុមហ៊ុនជាតិធានារ៉ាប់រងកម្ពុជា «កាមិនកូ» ក្នុងកំរិតទឹកប្រាក់ចំនួន ២៣.០០០.០០០.០០០៛(ម្ភៃបីពាន់លានរៀល) ដើម្បីបង្គ្រប់ចំនួន ២៨.០០០.០០០.០០០៛ (ម្ភៃប្រាំបីពាន់លានរៀល) ។ ទន្ទឹមគ្នានេះដែរ ក្រុមហ៊ុនកាមិនកូ ត្រូវផ្តល់នូវប័ណ្ណភាគហ៊ុនរបស់ខ្លួនមក ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលមានទឹកប្រាក់សរុបស្មើ ២៨.០០០.០០០.០០០៛ (ម្ភៃប្រាំបីពាន់លានរៀល) ដែលក្នុងនោះមាន ២៨០.០០០ ប័ណ្ណភាគហ៊ុន (ពីររយប៉ែតសិបពាន់ប័ណ្ណភាគហ៊ុន) និងមានតម្លៃនាមចារឹក ក្នុងមួយឯកតា ១០០.០០០៛ (មួយរយពាន់រៀល) ។

**ប្រការ ២-**

សញ្ញាប័ណ្ណរដ្ឋត្រូវបានបោះផ្សាយនៅថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០២ ចំនួន ២.៣០០ ប័ណ្ណ (ពីរពាន់បីរយប័ណ្ណ) ដោយមានតម្លៃនាមចារឹក ក្នុងមួយឯកតា ១០.០០០.០០០ ៛ (ដប់លានរៀល) ។

**ប្រការ ៣-**

សញ្ញាប័ណ្ណរដ្ឋត្រូវបានបោះផ្សាយសំរាប់រយៈពេល ០៣ ឆ្នាំ (បីឆ្នាំ) តាមឥណប្រតិទានកំណត់ក្នុង សញ្ញាប័ណ្ណ ។ ក្នុងរយៈពេលបីឆ្នាំនេះ អ្នកកាន់សញ្ញាប័ណ្ណ នឹងត្រូវបានទទួលការប្រាក់ប្រចាំឆ្នាំចំនួន ៣% (បីភាគរយ) ហើយការទូទាត់ការប្រាក់នេះត្រូវធ្វើឡើងជារៀងរាល់ ០៦ ខែ (ប្រាំមួយខែ) ម្តង ដោយឈរ លើមូលដ្ឋាន ០៦ ខែ ស្មើ ១៨០ ថ្ងៃ និង មួយឆ្នាំ ស្មើ ៣៦០ ថ្ងៃ ។

**ប្រការ ៤-**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានសិទ្ធិធ្វើសំណងសញ្ញាប័ណ្ណរដ្ឋមុនឥណប្រតិទាន ដែលបាន កំណត់ក្នុងសញ្ញាប័ណ្ណ គឺអាស្រ័យដោយស្ថានភាពថវិការបស់រដ្ឋ ។

**ប្រការ ៥-**

នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ទទួលបន្ទុកតាមដានរាល់ស្ថានភាពបំណុលនៃសញ្ញាប័ណ្ណរដ្ឋព្រម ទាំងធ្វើរបាយការណ៍ជូននាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ (ការិយាល័យគ្រប់គ្រងបំណុល) ។

**ប្រការ ៦-**

ប្រកាសនេះមានប្រសិទ្ធភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**គាត ឈន់**

**ចម្លងជូន**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមហ៊ុនជាតិធានារ៉ាប់រងកម្ពុជា- ឯកសារ- កាលប្បវត្តិ